៤០១.៦.២០១៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ :៦៨០

ចុះថ្ងៃទី៣០-០៧-២០១៣

សាល់ដីកា

លេខ : ២៨ ក្រIV "ច"

ចុះថ្ងៃទី ០៩-០៤-២០១៤

# គាំងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្ដីដែលប្រកាសឱ្យប្រើ តាមក្រិត្យលេខ: ០៦ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ដោយមាន ៖

## សមាសភាពក្រុមប្រឹក្សា

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

## ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ : ៦៨០ ចុះថ្ងៃទី៣០-០៧-២០១៣ រវាង៖

- ជនជាប់ចោទឈ្មោះ[redacted] Walter ភេទប្រុស អាយុ៦១ឆ្នាំ ជនជាតិអាឡឺម៉ង់ មុខរបរជាងថតរូប ទីលំនៅសព្វថ្ងៃស្នាក់នៅផ្ទះសំណាក់ណារិន រាជធានីភ្នំពេញ ។

<u>ជាប់ចោទពីបទ</u> : អំពើអនាចារ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៧ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា៨ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និង ធ្វើអាជីវកម្មលើមនុស្ស។

មានលោកស្រី[redacted] វិមានចំប៉ា ជាមេធាវីការពារសិទ្ធិ ។

អ្នកបកប្រែឈ្មោះ [redacted] ស្រីលាភ ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] ផន ភេទស្រី ទីលំនៅសព្វថ្ងៃផ្ទះជួល ផ្លូវលំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] មួយ ហៅ [redacted] មួយ ភេទ ស្រី អាយុ ១៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះជួល ផ្លូវលំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

មានលោកស្រី [redacted] សូនី ជាមេធាវីការពារសិទ្ធិ ។/

ឯរឿងហេតុមានដូចតទៅ ៖

កាលពីថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០០៧ សមត្ថកិច្ចបានធ្វើការបង្ក្រាប និងឃាត់ខ្លួនជនល្មើសម្នាក់ដែលមានឈ្មោះ [redacted] Walter ភេទប្រុស ជនជាតិអាឡឺម៉ង់ ដែលបានប្រព្រឹត្តអំពើអនាចារលើកុមារីម្នាក់ឈ្មោះ [redacted]មួយ អាយុ ១៤ឆ្នាំ នៅក្នុងផ្ទះសំណាក់ណារិន បន្ទប់លេខ ១១៣ ក្នុងរាជធានីភ្នំពេញ ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៖ ២២ "ក្រ៤" ចុះថ្ងៃទី១៣-០៣-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចខាងក្រោម:

១/ ផ្តន្ទាទោសលើឈ្មោះ [redacted] Walter ភេទប្រុស អាយុ៦១ឆ្នាំ ជនជាតិអាឡឺម៉ង់ ដាក់ពន្ធនាគារកំណត់រយៈពេល ១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៧ ពីបទអំពើអនាចារ (អនីតិជន) ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ណារិន ក្រុងភ្នំពេញ កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៧ តាមមាត្រា ៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងធ្វើអាជីវកម្មលើមនុស្ស

២/ បង្គាប់ឱ្យឈ្មោះ [redacted]Walter សងប្រាក់ថ្លៃខូចខាតកិត្តិយស សេចក្តីថ្លៃថ្នូរ និងជម្ងឺចិត្តសរុប ៧,០០០$ (ប្រាំពីរពាន់ដុល្លារអាមេរិក) ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផន ហៅ [redacted] ផន គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរតទៅ សំណូមពរលើសពីនេះ តុលាការបដិសេធចោល។

៣/ បង្គាប់ឱ្យមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចចាប់បញ្ជូនឈ្មោះ [redacted] Walter ចេញពីព្រះរាជាណាចក្រកម្ពុជា នៅពេលឈ្មោះនេះបានអនុវត្តទណ្ឌកម្មនៃទោសខាងលើចប់ជាស្ថាពរ។

៤/ វត្ថុតាងរួមមាន៖

ក. កំព្យូទ័រម៉ាក Amadeus ចំនួន ០១គ្រឿង និងទូរស័ព្ទដៃ Nokia ចំនួន ០១គ្រឿង សម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋនៅពេលសាលក្រមស្ថាពរតទៅ។

ខ. រូបថតកុមារមួយចំនួន, ឯកសារមួយចំនួន, ថ្នាំពេទ្យមួយចំនួន, កាសែតវីដេអូចំនួន២៤ដុំ, ផ្លាសចំនួន០២គ្រឿង, ហាតឌីសលេខ៣-៥ លេខ ៦០៤៦៨៦ ចំនួន ០២គ្រឿង។

គ. លិខិតឆ្លងដែនលេខ៦០០៤៥៤១០០៦ និងជើងកាមេរ៉ាចំនួន ០១ ត្រូវសម្រេចឱ្យទៅសាមីខ្លួនវិញនៅពេលអនុវត្តទណ្ឌកម្មនៃទោសចប់សព្វគ្រប់។

៥/ សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនត្រូវចោទ និងមេធាវី ចំពោះមុខជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី សម្រេចទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៥៩ ក្រ៦ "ប" ចុះថ្ងៃទី២២-១២-២០១១ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីដូចខាងក្រោម ៖

១/ ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៨ របស់ជនជាប់ចោទឈ្មោះ[redacted]Walter ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២/ តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២២ "ក្រ៤" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

៣/ បន្តឃុំខ្លួនជនជាប់ចោទ។

៤/ សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ប្រកាសជាសាធារណៈថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១៥៤ ចុះថ្ងៃទី០៥-០៧-២០១៣ របស់តុលាការកំពូល បានសម្រេចសេចក្តី ដូចខាងក្រោម ៖

១/ ទទួលផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ ០៦ ចុះថ្ងៃទី០៦-០១-២០១២ របស់លោកមេធាវី [redacted]ហាវុឌ្ឍី ។

២/ តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៥៦ "ក្រ៤" ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ លើកលែងតែចំណុចទី១ នៃសាលក្រមព្រហ្មទណ្ឌលេខ២២ "ក្រ៤" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ស្តីពីការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] Walter ត្រូវបដិសេធចោល។

៣/ បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ២៨៤ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះសាជាថ្មីតាមចំណុចខាងលើ។

៤/ សាលដីកានេះ ជំនុំជម្រះនាថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៣។

បានឃើញ របាយការណ៍រឿង របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី២៧-១២-២០១៣

បានឃើញ សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី០២-១០-២០០៩

## នាពេលសវនាការ

- ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿងក្តី
- ជនជាប់ចោទឈ្មោះ [redacted] Walter បានឆ្លើយថា : ខ្លួនបានជាប់ឃុំជិតប្រាំពីរឆ្នាំហើយ គឺដល់ថ្ងៃទី១១-០៤-២០១៤នេះ គ្រប់៧ឆ្នាំហើយ ។ ខ្លួនសុំឱ្យតុលាការផ្តន្ទាទោសខ្លួនត្រឹម៧ឆ្នាំគត់ ។
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផន បានឆ្លើយថា : ខ្លួនសុំឱ្យជនជាប់ចោទផ្តល់សំណងមកឱ្យខ្លួនឱ្យបានឆាប់ ព្រោះគ្រួសារខ្លួនកំពុងជួបការខ្វះខាត ។
- តំណាងមហាអយ្យការសន្និដ្ឋានថា : សុំសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិចារណា និងសម្រេចតាមការចង្អុលបង្ហាញរបស់តុលាការកំពូល ។
- លោកស្រី [redacted]ចំប៉ា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋានថា : តាមការចង្អុលបង្ហាញរបស់តុលាការកំពូល គឺឱ្យសាលាឧទ្ធរណ៍សម្រេចអំពីទណ្ឌកម្មលើកូនក្តីខ្លួនតាមច្បាប់ថ្មី ហេតុនេះខ្លួនសំណូមពរឱ្យក្រុមប្រឹក្សាពិចារណា និងសម្រេចតាមការចង្អុលបង្ហាញរបស់តុលាការកំពូល និងអនុវត្តតាមមាត្រា៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ ដែលផ្តន្ទាទោសកំណត់ពី២ឆ្នាំ ទៅ៧ឆ្នាំ ពីបទ ទិញអាពេស្យាចារ ។
- លោកស្រី [redacted] សុនី មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ បានសន្និដ្ឋានថា : ខ្លួនមិនជំទាស់នឹងការចង្អុលបង្ហាញរបស់តុលាការកំពូលទេ ប៉ុន្តែខ្លួនសំណូមពរឱ្យក្រុមប្រឹក្សាសម្រេចអំពីបញ្ហាសំណងឱ្យជនរងគ្រោះឱ្យបានឆាប់ ព្រោះសំណុំរឿងមានរយៈពេលយូរឆ្នាំមកហើយ រីឯគ្រួសាររបស់ជនរងគ្រោះ គឺកំពុងមានការខ្វះខាត ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីទាំងសងខាង
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិចារណាលើគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>សំអាងហេតុ</u>

យល់ឃើញថា

១- តុលាការកំពូលបានសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៥៦ “ក្រ៤” ចុះថ្ងៃទី២២-១២-២០១១ របស់សាលាឧទ្ធរណ៍ លើកលែងតែចំណុចទី១ នៃសាលក្រមព្រហ្មទណ្ឌលេខ ២២ “ក្រ៤” ចុះថ្ងៃទី១៣-០៣-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ស្តីពីការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] Walter ត្រូវបដិសេធចោល ហើយបង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ២៤៨ ចុះថ្ងៃទី ១២-១២-២០១២ របស់តុលាការកំពូល មកឱ្យសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះសាជាថ្មីឡើងវិញ លើចំណុចខាងលើ ។ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ១៥៤ ចុះថ្ងៃទី ០៥-០៧-២០១៣ របស់តុលាការកំពូល និងតាមមាត្រា៤៣៩ និងមាត្រា៤៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- តុលាការកំពូលបានចង្អុលបង្ហាញឱ្យ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ធ្វើការជំនុំជម្រះជាថ្មីឡើងវិញ លើចំណុចផ្តន្ទាទោសដាក់ពន្ធនាគារចំពោះជនជាប់ចោទឈ្មោះ [redacted] Walter ។ ដូចនេះ សាលាឧទ្ធរណ៍ពិចារណាតែទៅលើចំណុចដាក់ទណ្ឌកម្មនេះ តាមការចង្អុលបង្ហាញរបស់តុលាការកំពូលប៉ុណ្ណោះ ។ រីឯអង្គហេតុនៃរឿង មានលក្ខណៈស្ថាពរហើយ មានន័យថា : មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពលើជនជាប់ចោទពីបទ : ទិញពេស្យាចារកុមារ ដោយប្រព្រឹត្តអំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងភេទជាមួយនឹងអនីតិជន អាយុតិចជាង១៥ឆ្នាំ ។

៣- តំណាងមហាអយ្យការបានសន្និដ្ឋានសុំឱ្យសភាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ធ្វើការពិចារណា និងសម្រេចតាមការចង្អុលបង្ហាញរបស់តុលាការកំពូល ដែលយោងតាមមាត្រា១០នៃក្រមព្រហ្មទណ្ឌ ។ គប្បីក្រុមប្រឹក្សាពិចារណា និងសម្រេច ។

៤- ការលើកឡើងរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទថា : ការចង្អុលបង្ហាញរបស់តុលាការកំពូល ឱ្យសាលាឧទ្ធរណ៍សម្រេចអំពីទណ្ឌកម្មតាមច្បាប់ថ្មី ដោយអនុវត្តតាមមាត្រា១០ នៃក្រមព្រហ្មទណ្ឌ និងបានសំណូមពរឱ្យក្រុមប្រឹក្សាពិចារណា និងសម្រេចតាមមាត្រា៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ ។ គប្បីក្រុមប្រឹក្សាពិចារណា និងសម្រេច ។

៥- ក្រុមប្រឹក្សាយល់ឃើញថា ការចង្អុលបង្ហាញរបស់តុលាការ ដែលឱ្យសាលាឧទ្ធរណ៍ជំនុំជម្រះសាជាថ្មីឡើងវិញ លើចំណុចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] Walter ដោយយោងតាមមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ ដែលក្រុមប្រឹក្សាគប្បីសម្រេចតាមការចង្អុលបង្ហាញនេះ ដោយពិចារណាលើមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ ដែលគប្បីសម្រេចពិចារណាលើផ្តន្ទាទោសជនជាប់ចោទរូបនេះ ត្រឹមកម្រិតអប្បបរមានៃទោស ដោយហេតុថា អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] Walter មិនមានលក្ខណៈធ្ងន់ធ្ងរពេកនោះទេ ម្យ៉ាងទៀតជនជាប់ចោទបានសារភាពទទួលស្គាល់កំហុសរបស់ខ្លួន មិននាំឱ្យមានការលំបាកដល់នីតិវិធីតុលាការ រីឯមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ ក៏មិនបានជំទាស់ដែរ ដែលគប្បីតុលាការពិចារណា ដើម្បីជាគំរូដល់ជនជាប់ចោទដទៃទៀត ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១- ទទួលជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌ លេខ ៦៨០ ចុះថ្ងៃទី ៣០-០៧-២០១៣ របស់សាលាឧទ្ធរណ៍ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ១៥៤ ចុះថ្ងៃទី០៥-០៧-២០១៣ របស់តុលាការកំពូល និងតាមមាត្រា ៤៣៩, មាត្រា ៤៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] Walter ភេទប្រុស អាយុ៦១ឆ្នាំ ជនជាតិអាឡឺម៉ង់ ដាក់ពន្ធនាគារកំណត់០៧ (ប្រាំពីរ)ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី១០-០៤-២០០៧ ពីបទ : ទិញពេស្យាចារកុមារ តាមមាត្រា១០នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៩-០៤-២០១៤ នៅចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកាស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ៕

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

---

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]